អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

D381/16

**តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្ដីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦១)

**<u>អង្គបុរេជំនុំជម្រះ</u>**

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន**
**ចៅក្រម Olivier BEAUVALLET**
**ចៅក្រម នៃយ ថុល**
**ចៅក្រម Kang Jin BAIK**
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 10 / 2019
ម៉ោង (Time/Heure): 16 : 20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ**

**សេចក្ដីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ បណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤**

---

**<u>សហព្រះរាជអាជ្ញា:</u>**

ជា លាង
Brenda J. HOLLIS

**<u>សហមេធាវីការពារក្ដី យឹម ទិត្យ:</u>**

សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**<u>មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រ៊ីនណា
វ៉េន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ" ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៩ ("សំណើ")[1]។

1. នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចំនួនពីរផ្ទុយគ្នាដាច់ដោយឡែកពីគ្នានៅក្នុងសំណុំរឿង ០០៤។ ខណៈដែលសហចៅក្រមស៊ើបអង្កេតជាតិបានចេញ "ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ" ("ដីកាលើកលែងចោទប្រកាន់")[2] ជាភាសាខ្មែរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានចេញ "ដីកាដំណោះស្រាយ"របស់គាត់[3] ជាភាសាអង់គ្លេស (ជារួមហៅថា "ដីកាដំណោះស្រាយ")។

2. នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៩ អង្គបុរេជំនុំជម្រះបានបង្គាប់ឲ្យភាគីដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤ នៅក្នុងរយៈពេលដប់បួនថ្ងៃ បន្ទាប់ពីមានការជូនដំណឹងអំពីសំណៅបកប្រែដីកាដំណោះស្រាយទាំងពីរនេះ[4]។

3. នៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ "សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ

---

[1] សំណុំរឿង ០០៤/០៧-០៩-២០០៩-អវតក/កសចស("សំណុំរឿង ០០៤") សំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារ D381/8 និង D382/10 ("សំណើ")។

[2] សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩ ឯកសារ D381។

[3] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩ ឯកសារ D382។

[4] សំណុំរឿង ០០៤ សេចក្ដីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពន្យារកាលបរិច្ឆេទសម្រាប់ការជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារ D381/3 និង D382/3។ សូមមើលផងដែរ សំណុំរឿង ០០៤ សំណើរបស់ យឹម ទិត្យ សុំពន្យារពេលនៃកាលបរិច្ឆេទសម្រាប់ការជូនដំណឹងអំពីការប្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៩ និងបានដាក់ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារ D381/1 និង D382/1។

01630057



របស់សហចៅក្រមស៊ើបអង្កេតជាតិ"[5] ហើយនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៩ សហមេធាវីការពារក្តី យឹម ទិត្យ ("សហមេធាវីការពារក្តី") បានដាក់ "ការជូនដំណឹងរបស់ខ្លួនអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤"[6]។ សហព្រះរាជអាជ្ញាជាតិបានដាក់ "បណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ក្នុងសំណុំរឿង០០៤"[7] នៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩ បន្ទាប់ពីមានការជូនដំណឹងរបស់គាត់[8] ដែលបានដាក់នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៩។

4. សំណៅបកប្រែជាភាសាខ្មែរនៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបានដាក់នៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៩ ហើយបានជូនដំណឹងដល់ភាគី នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៩។ សំណៅបកប្រែជាភាសាអង់គ្លេសនៃដីកាសម្រេចលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ត្រូវបានដាក់ និងជូនដំណឹង នៅថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០១៩។

[5] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ (D381) ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/4។

[6] សំណុំរឿង ០០៤ ការជូនដំណឹងរបស់ យឹម ទិត្យ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារ D381/7។ សំណុំរឿង ០០៤ ការជូនដំណឹងរបស់ យឹម ទិត្យ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៩ ឯកសារ D382/9។

[7] សំណុំរឿង ០០៤ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង០០៤ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៩ ឯកសារ D382/4/1។

[8] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងរបស់ សហព្រះរាជអាជ្ញាជាតិ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៩ ឯកសារ D382/4។

5. នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៩ សហមេធាវីការពារក្តីបានដាក់សំណើ[9]។ សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបនៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៩ ("ចម្លើយតប")[10] ហើយសហមេធាវីការពារក្តីបានធ្វើការឆ្លើយតបនៅថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១៩៩ ("ការឆ្លើយតប")[11]។

6. នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៩ អង្គបុរេជំនុំជម្រះបានបង្គាប់ឲ្យផ្អាកកាលបរិច្ឆេទកំណត់សម្រាប់ភាគីក្នុងការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ រហូតដល់ពេលមានការជូនដំណឹងពីអង្គភាពបកប្រែភាសាអំពីឯកសារបកប្រែជាភាសាអង់គ្លេសដែលត្រឹមត្រូវ សម្រាប់ដីកាសម្រេចលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ[12]។

7. នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ ការបកប្រែដែលបានកែតម្រូវនៃដីកាលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិត្រូវបានដាក់ និងជូនដំណឹងដល់ភាគី។

8. សហមេធាវីស្នើសុំថា សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនជំទាស់ទៅនឹងដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះគួរអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនអនុលោមតាមមាត្រា ៥(៤) នៃសេចក្តីណែនាំអនុវត្តស្តីពីការ

---

[9] សំណើ កថាខណ្ឌ ១៥, ១៦, ២៨។

[10] សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមទំព័រ និងពេលវេលាកំណត់ចំពោះបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារ D381/13 និង D382/16។

[11] សំណុំរឿង ០០៤ ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ចំពោះបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១៩ ឯកសារ D381/15 និង D382/18។

[12] សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំឲ្យអង្គបុរេជំនុំជម្រះបង្គាប់បញ្ជាបន្ទាន់ឲ្យផ្តល់នូវការបកប្រែដោយត្រឹមត្រូវជាភាសាអង់គ្លេស នូវដីកាសម្រេចលើកលែងចោទប្រកាន់ចំពោះ យឹម ទិត្យ និងផ្អាកកាលបរិច្ឆេទកំណត់នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារ D381/12 និង D382/13។ សូមមើល ផងដែរ សំណុំរឿង ០០៤ សំណើរបស់ យឹម ទិត្យ សុំឲ្យអង្គបុរេជំនុំជម្រះបង្គាប់បញ្ជាបន្ទាន់ឲ្យផ្តល់នូវការបកប្រែជាភាសាអង់គ្លេសនៃដីកាសម្រេចលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិដែលត្រឹមត្រូវ និងផ្អាកកាលបរិច្ឆេទកំណត់នៃបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារ D381/5 និង D382/5។ សំណុំរឿង ០០៤ សំណុំរឿង ០០៤ សារអេឡិចត្រូនិករបស់ ក.ស.ព ស្តីពីការកែតម្រូវសំណៅបកប្រែដីកាសម្រេចលើកលែងការចោទប្រកាន់ សំណុំរឿង ០០៤ (ឯកសារD381) ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១៩ ឯកសារ D382/6។

ដាក់ឯកសារ និង វិធាន ៣៩(៤) និង ៧៥(៣) នៃវិធានផ្ទៃក្នុង ដើម្បីបង្កើនចំនួនទំព័រពី ៣០ ទៅដល់ ១៥០ ទំព័រ និងបន្ថែមពេលវេលាពី ៣០ ទៅ ៤៥ ថ្ងៃ ដោយចាប់ផ្តើមគិតពីថ្ងៃទទួលបានការបកប្រែដីកាដំណោះស្រាយទាំងពីរ[13]។ ពួកគេលើកឡើងថា (i) ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និងដោយឡែកពីគ្នា[14] (ii) វិសាលភាព និងភាពស្មុគ្រស្មាញនៃដីកាដំណោះស្រាយ[15] និង (iii) វិសាលភាពធំធេង និងភាពស្មុគ្រស្មាញដែលជាផលវិបាកនៃបណ្តឹងឧទ្ធរណ៍ដ៏ចាំបាច់នេះ[16] បង្កើតជាកាលៈទេសៈពិសេសដែលធ្វើយុត្តិកម្មដល់សំណើនេះ។

9. សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា ទោះបីគាត់មិនជំទាស់ជាទូទៅចំពោះសំណើ ដោយពិចារណាពី "សភាពខុសគ្នានៃដីកាដំណោះស្រាយទាំងពីរ" ក៏ដោយ តែសហមេធាវីគួរលើកឡើងនូវបណ្តឹងឧទ្ធរណ៍ពីររបស់ខ្លួនជំទាស់ទៅនឹងដីកាដំណោះស្រាយនីមួយៗ ជាឯកសារពីរដាច់ដោយឡែកពីគ្នា ដោយបណ្តឹងឧទ្ធរណ៍នីមួយៗមិនលើសពី ១០០ ទំព័រនោះទេ ដើម្បីឱ្យអង្គបុរេជំនុំជម្រះ និងភាគីអាចបែងចែកច្បាស់លាស់នូវទឡ្ហីករណ៍របស់ខ្លួន ពាក់ព័ន្ធនឹងដីកាដំណោះស្រាយនីមួយៗ[17]។ សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំបន្ថែមថា អង្គជំនុំជម្រះគួរតែធ្វើសមកាលកម្មពីខ្សែបន្ទាត់ពេលវេលាចំពោះសារណាបណ្តឹងឧទ្ធរណ៍របស់ភាគីនានា[18]។

10. សហមេធាវីធ្វើការឆ្លើយតបថា សហព្រះរាជអាជ្ញាអន្តរជាតិ (i) បញ្ជាក់មិនត្រឹមត្រូវអំពីសំណើរបស់ខ្លួន[19] (ii) ស្នើឡើងមិនសមស្របឱ្យអង្គបុរេជំនុំជម្រះកែតម្រូវដំណោះស្រាយដែលស្នើនៅក្នុងសំណើសុំរបស់ខ្លួន និងបង្គាប់ឱ្យសហមេធាវីដាក់បណ្តឹងឧទ្ធរណ៍ពីរ ជាឯកសារពីរដាច់ពីគ្នា[20] និង (iii) លើកឡើងដោយមិនសមស្របអំពីសំណើសុំដែលពុំពាក់ព័ន្ធនៅក្នុងចម្លើយតបរបស់ខ្លួន ដោយ

[13] សំណើ កថាខណ្ឌ ១៥, ១៦, ២៨។

[14] សំណើ កថាខណ្ឌ ១៧-២២។

[15] សំណើ កថាខណ្ឌ ១៧, ២៣-២៤។

[16] សំណើ កថាខណ្ឌ ១៧, ២៥-២៧។

[17] ចម្លើយតប កថាខណ្ឌ ២។

[18] ចម្លើយតប កថាខណ្ឌ ៣។

[19] ការឆ្លើយតប កថាខណ្ឌ ៣-៤។

[20] ការឆ្លើយតប កថាខណ្ឌ ៥-៧។

មិនបានដាក់សំណើរបស់ខ្លួន[21]។ អនុលោមតាមសំអាងហេតុទាំងនេះ សហមេធាវីស្នើសុំដល់អង្គជំនុំជម្រះមេត្តាច្រានចោលចម្លើយតប ដោយសារពុំមានភាពពាក់ព័ន្ធ[22]។

11. អនុលោមតាមវិធាន ៣៩(២) និង (៤) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះអាចកំណត់ពេលវេលាសម្រាប់ដាក់ឯកសារពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍បាន។ អនុលោមតាមមាត្រា ៥.៤ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ អង្គជំនុំជម្រះអាចបង្កើនចំនួនទំព័រឯកសារបាន នៅក្នុងកាលៈទេសៈពិសេស។

12. តាំងពីដំបូងមក អង្គបុរេជំនុំជម្រះរម្លឹកដល់វិធាន ៦៧(១) និង ៧៤ នៃវិធានផ្ទៃក្នុង និងកត់សម្គាល់នូវសភាពផ្ទុយគ្នានៃដីកាដំណោះស្រាយទាំងពីរនៅក្នុងសំណុំរឿង ០០៤ ដែលអាចតម្រូវឱ្យអនុវត្តនូវជំហាននីតិវិធីផ្សេងៗគ្នាក្នុងការដោះស្រាយចំពោះសារណាបណ្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយនីមួយៗ។ ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ការអនុញ្ញាតឲ្យដាក់បណ្ដឹងឧទ្ធរណ៍រួមគ្នាជំទាស់ទៅនឹងដីកាដំណោះស្រាយទាំងពីរ ពុំមែនជាការត្រឹមត្រូវទេ ហើយសន្និដ្ឋានថាភាគីគួរលើកឡើងនូវដីកាដំណោះស្រាយនីមួយៗដាច់ដោយឡែកពីគ្នា។

13. ពាក់ព័ន្ធនឹងចំនួនទំព័រ និងពេលវេលាកំណត់វិញ អង្គបុរេជំនុំជម្រះកត់សម្គាល់អំពីទំហំនិងភាពស្មុគស្មាញនៃដីកាដំណោះស្រាយទាំងពីរ ទាក់ទិននឹងវិសាលភាព និងភាពធំធេងនៃបញ្ហាអង្គហេតុនិងអង្គច្បាប់ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយទាំងនោះ ព្រមទាំងភារកិច្ចរបស់អង្គជំនុំជម្រះក្នុងការរក្សាតុល្យភាពរវាងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី។ ហេតុនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា វាជាការចាំបាច់ដែលត្រូវអនុញ្ញាតឲ្យភាគីទទួលបានពេលវេលាបន្ថែម និងការបង្កើនចំនួនទំព័រ ដើម្បីដាក់បណ្ដឹងឧទ្ធរណ៍របស់ខ្លួន។

14. ទោះជាយ៉ាងណាក្ដី អង្គបុរេជំនុំជម្រះយល់ឃើញថា គុណភាព និងប្រសិទ្ធភាពនៃសារណាបណ្ដឹងឧទ្ធរណ៍ពុំមែនអាស្រ័យទៅលើទំហំរបស់វាទេ តែផ្ទុយទៅវិញគឺអាស្រ័យទៅលើការបង្ហាញអំពី

---

[21] ការឆ្លើយតប កថាខណ្ឌ ៨-៩។

[22] ការឆ្លើយតប ទំព័រ ៤។

ភាពច្បាស់លាស់ និងភាពសមហេតុផល ហេតុនេះហើយសារណាដែលវែងហួសហេតុពុំបានជួយសម្រួលដល់ផ្នែករដ្ឋបាលតុលាការប្រកបដោយប្រសិទ្ធភាពឡើយ[23]។

15. ហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីជាប្រយោជន៍យុត្តិធម៌ និងដើម្បីរក្សាតុល្យភាពរវាងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងប្រសិទ្ធភាពនោះ ជាការត្រឹមត្រូវដែលផ្តល់ដល់ភាគីទាំងអស់នូវការបង្កើនចំនួន ៧០ ទំព័រ បន្ថែមទៀត និង បន្ថែមរយៈពេល ១៥ ថ្ងៃ ថែមទៀត គិតចាប់ពីការជូនដំណឹងអំពីសំណៅបកប្រែជាភាសាអង់គ្លេសដែលបានកែតម្រូវនៃដីកាលើកលែងចោទប្រកាន់ នៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៩ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួនជំទាស់ទៅនឹងដីកាដំណោះស្រាយជាឯកសារពីរដាច់ដោយឡែកពីគ្នា។

---

[23] *សូមមើល* យន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ (MICT) *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Karadžić* សំណុំរឿងលេខ MICT-13-55-A សេចក្តីសម្រេចទៅលើសំណើសុំបង្កើនចំនួនអក្សរកំណត់ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ ២០១៦ ទំព័រ ២។

01630062

សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦១)

ឯកសារលេខ D381/16

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**ទទួលយក** ផ្នែកខ្លះនៃសំណើ។

**បង្គាប់ឲ្យ** ភាគីដាក់បណ្តឹងឧទ្ធរណ៍ដោយឡែកពីគ្នាជំទាស់ទៅនឹងដីកាដំណោះស្រាយ ជាឯកសារពីរដាច់ដោយឡែកពីគ្នា។

**អនុញ្ញាតឲ្យ** ភាគីដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយក្នុងរយៈពេល ៤៥ ថ្ងៃ ចាប់គិតពីការជូនដំណឹងពីសំណៅបកប្រែជាភាសាអង់គ្លេសដែលបានកែតម្រូវនៃដីកាលើកលែងចោទប្រកាន់ នៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៩។

**អនុញ្ញាតឲ្យ** ភាគីដាក់សារណាបណ្តឹងឧទ្ធរណ៍ចំនួន ១០០ ទំព័រ។

**ណែនាំឲ្យ** អង្គភាពបកប្រែភាសាធានាថា អាចបញ្ចប់ការបកប្រែដែលស្នើឡើងក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីពេលដាក់បណ្តឹងឧទ្ធរណ៍។

**បដិសេធ** ផ្នែកផ្សេងទៀតនៃសំណើនេះ។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គិមសាន** **Olivier BEAUVALLET** **ន័យ ធុល** **Kang Jin BAIK** **ហួត វុទ្ធី**